# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ការអញ្ជើញឲ្យដាក់សំណើដេញថ្លៃ

## ការអញ្ជើញលេខៈ CDRR/KPT-ROAD-0605

## លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## គម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅសហគមន៍មូលដ្ឋាន

## សមាសភាព C

**មូលនិធិលេខៈ9178-CAM**

មានបំណងជ្រើសរើសអ្នកទទួលការដើម្បីអនុវត្តការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធដូចខាងក្រោមៈ ឈ្មោះកិច្ចសន្យាៈជួសជុលផ្លូវដីក្រាលក្រួសក្រហមប្រវែង១២៥០ម៉ែត្រ ទទឹងផ្លូវប្រវែង៤,៥ម៉ែត្រ និងសាងសង់ស្ពានបេតុងទំហំប្រវែង ៤x៦ ម៉ែត្រ ចំនួន១កន្លែង ស្ថិតក្នុងភូមិថ្នល់បែក ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។

១ រាជរដ្ឋាភិបាលកម្ពុជាបានទទួលជំនួយឥតសំណងពីធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់ការចំណាយលើ គម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅសហគមន៍មូលដ្ឋាន ហើយមានបំណងប្រើប្រាស់មួយផ្នែកនៃជំនួយឥតសំណងនេះ សម្រាប់ចំណាយលើកិច្ចសន្យា ជួសជុលផ្លូវដីក្រាលក្រួសក្រហមប្រវែង១២៥០ម៉ែត្រ ទទឹងផ្លូវប្រវែង ៤,៥ម៉ែត្រ និង សាងសង់ស្ពានបេតុងទំហំប្រវែង ៤x៦ ម៉ែត្រ ចំនួន១កន្លែង (CDRR/KPT-ROAD-0602)។

២ តម្លៃប៉ាន់ស្មានសម្រាប់កិច្ចសន្យានេះគឺ៣០.៦៨៥,៣០ដុល្លារ(សាមសិបពាន់ប្រាំមួយរយប៉ែតសិបប្រាំដុល្លារអាមេរិក)។

៣ កាលវិភាគសាងសង់មានរយៈពេល ៣ខែ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើម។

៤ អ្នកទទួលការមានសិទ្ធិ និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានចំណាប់អារម្មណ៍ត្រូវបានអញ្ជើញឱ្យមកទទួលយកឯកសារដេញថ្លៃចំនួនមួយច្បាប់ដោយឥតគិតថ្លៃនៅអាសយដ្ឋានខាងក្រោម។

៥ ដើម្បីក្លាយជាអ្នកដែលមានសិទ្ធិអ្នកទទួលការត្រូវៈ
ក.បានចុះបញ្ជីការស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
ខ.មិនឋិតនៅក្រោមការហាមឃាត់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ឬ ធនាគារអភិវឌ្ឍន៍អាស៊ី។

៦ ដើម្បីចាត់ទុកជាអ្នកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អ្នកទទួលការត្រូវៈ
ក.ក្នុងរយៈពេល៣ឆ្នាំចុងក្រោយធ្លាប់បានបញ្ចប់កិច្ចសន្យាយ៉ាងតិចចំនួន២ នៃប្រភេទការងារប្រហាក់ប្រហែលគ្នា ដែលកិច្ចសន្យានិមួយៗមានតម្លៃយ៉ាងតិច ៧៥% នៃតម្លៃដាក់ដេញថ្លៃ ។
ខ.ក្នុងរយៈពេល ២ឆ្នាំ ចុងក្រោយធ្លាប់បានបញ្ចប់កិច្ចសន្យាដែលមានតម្លៃសរុបយ៉ាងតិចស្មើ ១.៥ ដងនៃតម្លៃដាក់ដេញថ្លៃ ។
គ.អ្នកគ្រប់គ្រងសំណង់ដែលស្នើមកត្រូវមានបទពិសោធន៍យ៉ាងតិច ៣ឆ្នាំ ក្នុងការត្រួតពិនិត្យការងារដែលមានលក្ខណៈប្រហាក់ប្រហែល និងធ្លាប់មានតួនាទីជាអ្នកគ្រប់គ្រងការងារសំណង់ក្នុងរយៈពេលមិនតិចជាង ១ឆ្នាំ ។ ឯកសារដែលជាភស្តុតាងបង្ហាញអំពីលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃត្រូវដាក់ភ្ជាប់មកជាមួយសំណើដេញថ្លៃ។

៧ សំណើដេញថ្លៃទាំងអស់ត្រូវដាក់មកអាស័យដ្ឋានខាងក្រោមនៅត្រឹមឬមុនម៉ោង ៩:០០ព្រឹក ថ្ងៃទី...១១..... ខែកក្កដា ឆ្នាំ ២០១៧។ សំណើដេញថ្លៃណាដែលដាក់មកយឺត នឹងត្រូវបានបដិសេធចោល។ សំណើដេញថ្លៃដែលបានទទួល នឹងត្រូវបានបើកជាសាធារណៈភ្លាមៗក្រោយកាលបរិច្ឆេទផុតកំណត់ នៅអាស័យដ្ឋានដដែលដោយមានវត្តមាន តំណាងអ្នកដេញថ្លៃទាំងអស់ ហើយអ្នកទទួលផលគម្រោងពីសហគមន៍មូលដ្ឋានដែលពាក់ព័ន្ធដែលមានបំណងចង់ចូលរួមត្រូវបានអនុញ្ញាតិអោយចូលរួមដោយផ្ទាល់ ។

<u>អាសយដ្ឋានសម្រាប់ដាក់សំណើដេញថ្លៃ និង បើកសំណើដេញថ្លៃគឺ:</u>

សាលាស្រុកកំពង់ស្វាយ ស្ថិតក្នុងភូមិព្រៃព្រាល"ខ" ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។
បន្ទប់: សាលប្រជុំសាលាស្រុកកំពង់ស្វាយ ។

៨ ម្ចាស់គម្រោងនឹងផ្តល់កិច្ចសន្យាដល់អ្នកដេញថ្លៃណាដែលត្រូវបានពិនិត្យឃើញថា សំណើដេញថ្លៃមានតម្លៃទាបជាងគេបំផុតនឹងឆ្លើយតបទាំងស្រុងទៅតាមលក្ខខណ្ឌតម្រូវនានា នៃឯកសារដេញថ្លៃហើយអ្នកដេញថ្លៃនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការអនុវត្តកិច្ចសន្យាដោយការពេញចិត្ត ។

៩ សំណើដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវលិខិតប្រកាសស្តីពីការធានាសំណើដេញថ្លៃ និងការអនុវត្តន៍កិច្ចសន្យា (bid and performance securing declaration) ដូចបានរៀបរាប់ក្នុងសេចក្តីណែនាំសម្រាប់អ្នកដេញថ្លៃ (Instructions to Bidders)។ ចំពោះសំណើដេញថ្លៃណាដែលមិនបានភ្ជាប់មកនូវលិខិតប្រកាសស្តីពីការធានាសំណើរដេញថ្លៃនិងការអនុវត្តន៍កិច្ចសន្យានេះនឹងត្រូវបដិសេធចោលដោយចាត់ទុកថាមិនបានឆ្លើយតបតាមលក្ខខណ្ឌតម្រូវ ។

១០ អាសយដ្ឋានដើម្បីសាកសួរព័ត៌មាន និងទទួលយកឯកសារដេញថ្លៃគឺ៖
- **កញ្ញា ចែម ធីដែន**, មន្ត្រីអង្គភាពលទ្ធកម្មស្រុកកំពង់ស្វាយ
- **លោកស្រី តឹក បុផ្ផាមុន្នី**, ប្រធានការិយាល័យគាំទ្រផែនការឃុំ ស្រុកកំពង់ស្វាយ

អាសយដ្ឋានៈសាលាស្រុកកំពង់ស្វាយ ស្ថិតក្នុងភូមិព្រៃព្រាល"ខ"ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។
លេខទូរសព្ទ: ០១២ ៨៣៦៣៨៤, ០៨៩ ៦៣៨៣៦៣, ០៩៧ ៨២ ០៣ ៥២២
ម៉ោងការងារ ព្រឹកៈ ៧:៣០ - ១១:៣០ , ល្ងាចៈ ២:០០ - ៥:០០

១១ ក្នុងករណីដែលមានការលំបាកក្នុងការទទួលឯកសារដេញថ្លៃភាគីទាំងឡាយដែលមានចំណាប់អារម្មណ៍ អាចទាក់ទងជាលាយលក្ខណ៍អក្សរមក **ឯកឧត្តម នី គឹមសាន**, ប្រធានគម្រោង នៃលេខាធិការដ្ឋាន គ.ជ.អ.ប អាសយដ្ឋាន មហាវិថីនរោត្តម ចំការមន ភ្នំពេញ។
លេខទូរសព្ទ: ០១១ ៩៧០ ៥៦៥,
អ៊ីម៉ែល: kimsanny1973@gmail.com
និងផ្ញើឯកសារដែល ទំនាក់ទំនងនោះមួយច្បាប់ផងដែរទៅ **លោក យី សុខធារិទ្ធ**, ប្រធាននាយកដ្ឋានសហប្រតិបត្តិការពហុភាគីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្លូវ៩២, សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ភ្នំពេញ កម្ពុជា។
លេខទូរសព្ទ: (៨៥៥) ២៣ ៧២៤ ៦៦៤,
លេខទូរសព្ទដៃ: (៨៥៥) ១២ ៥៨៥ ៩៥៩
អ៊ីម៉ែល: sokthearith_yi@mef.gov.kh

១២ រាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី នឹងប្រកាសរៀងៗខ្លួនអំពីការដកសិទ្ធិទាំងស្រុងពីក្រុមហ៊ុនដោយមិនកំណត់ពេល ឬក្នុងរយៈពេលកំណត់ណាមួយ ពីការទទួលបានកិច្ចសន្យាដែលប្រើប្រាស់មូលនិធិរាជរដ្ឋាភិបាល

កម្ពុជានិងធានាគារអភិវឌ្ឍន៍អាស៊ី ប្រសិនបើនៅពេលណាមួយដែលពិនិត្យឃើញថាក្រុមហ៊ុននោះជាប់ពាក់ព័ន្ធនឹងអំពើពុករលួយ ឬអំពើកេងបន្លំ អំពើឃុបឃិត ឬអំពើបង្ខិតបង្ខំ ក្នុងការប្រកួតប្រជែងដើម្បីទទួលបានកិច្ចសន្យា ឬក្នុងពេលអនុវត្តកិច្ចសន្យា។

១៣ ភាគីពាក់ពន្ធ័អាចប្ដឹងតវ៉ានៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការលទ្ធកម្ម។ និតិវិធីនៃការប្ដឹងតវ៉ាបានរៀបរាប់ក្នុងប្រការ ២១ នៃសេចក្ដីណែនាំសម្រាប់អ្នកដេញថ្លៃ។ យើងខ្ញុំរង់ចាំទទួលសំណើដេញថ្លៃពេញលេញ និងឆ្លើយតបតាមលក្ខខណ្ឌតម្រូវមុនកាលបរិច្ឆេទផុតកំណត់ដែលបានបញ្ជាក់ខាងលើ និងតាមលក្ខខណ្ឌដែលបានរៀបរាប់ក្នុងឯកសារដេញថ្លៃ ។

យើងខ្ញុំរង់ចាំទទួលសំណើដេញថ្លៃពេញលេញ និងឆ្លើយតបតាមលក្ខខណ្ឌតម្រូវមុនកាលបរិច្ឆេទផុតកំណត់ដែលបានបញ្ជាក់ខាងលើ និងតាមលក្ខខណ្ឌដែលបានរៀបរាប់ក្នុងឯកសារដេញថ្លៃ ដោយសេចក្ដីរាប់អាន។

សាលាស្រុកកំពង់ស្វាយ ថ្ងៃទី ២៧... ខែ មិថុនា ឆ្នាំ ២០១៧

ហត្ថលេខា និង ត្រា

**អភិបាលស្រុក**

អ៊ុន-ប៊ុត